**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :........០២៩/២០........**ក.ប**/ស.ជ.ណ.ឈ.ភ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើក "វិធានការជាជំហានសម្រាប់ការស្នាក់នៅ" ប្រទេសជប៉ុន និងនីតិវិធីចំពោះកម្មសិក្សាការី-ពលករជំនាញកម្ពុជា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់សមាគមទីភ្នាក់ងារជ្រើសរើសឯកជន ទីភ្នាក់ងារជ្រើសរើសឯកជន និងកម្មសិក្សាការី-ពលករជំនាញដែលត្រៀមចេញដំណើរទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុនទាំងអស់ឱ្យបានជ្រាបថា តាមរយៈការជូនដំណឹងរបស់ស្ថានទូតនៃប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ រដ្ឋាភិបាលជប៉ុន បានសម្រេចអនុញ្ញាតបើក **"វិធានការជាជំហានសម្រាប់ការស្នាក់នៅ"** រយៈពេលយូរ សម្រាប់ប្រទេសកម្ពុជា ដែលរួមបញ្ចូលទាំងកម្មសិក្សាការី-ពលករជំនាញកម្ពុជា **ចាប់ពីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២០** នេះតទៅ ដោយត្រូវអនុវត្តទៅតាមនីតិវិធីដូចខាងក្រោម៖

- មុនពេលចេញដំណើរទៅប្រទេសជប៉ុន ត្រូវបំពេញពាក្យស្នើសុំទិដ្ឋាការថ្មី នៅស្ថានទូតនៃប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ដោយត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម៖
  - ១. លិខិតឆ្លងដែនរបស់កម្មសិក្សាការី-ពលករជំនាញ
  - ២. ពាក្យស្នើសុំទិដ្ឋាការ
  - ៣. វិញ្ញាបនបត្របញ្ជាក់ពីសិទ្ធរស់នៅ (Certificate of Eligibility) របស់កម្មសិក្សាការី-ពលករជំនាញ
  - ៤. កិច្ចសន្យាអនុវត្តវិធានការចត្តាឡីស័កចំនួន១៤ថ្ងៃ ដែលផ្តល់ឱ្យដោយក្រុមហ៊ុន ឬសមាគមនៅប្រទេសជប៉ុន (ចំនួន២ច្បាប់ គឺច្បាប់ដើម១ច្បាប់ និងច្បាប់ចម្លង១ច្បាប់)
  - ៥. កម្រងសំណួរបច្ចុប្បន្នភាពចុងក្រោយបំផុតស្តីពីប្រវត្តិ និងគម្រោងធ្វើដំណើរក្នុងអំឡុងពេលកូវីដ-១៩ ដែលកម្មសិក្សាការី-ពលករជំនាញ ត្រូវបំពេញ។

- ក្នុងអំឡុងពេលធ្វើដំណើរទៅប្រទេសជប៉ុន កម្មសិក្សាការី-ពលករជំនាញត្រូវអនុវត្តដូចខាងក្រោម៖
  - ១. បំពេញចម្លើយទៅក្នុងកម្រងសំណួរស្តីពីស្ថានភាពសុខភាពបច្ចុប្បន្ន ដែលបានចែកជូននៅលើយន្តហោះ ហើយត្រូវដាក់ជូនការិយាល័យទទួលបន្ទុកអនុវត្តចត្តាឡីស័កនៅព្រលានយន្តហោះវិញ។ កម្រងសំណួរនេះ ត្រូវបានរៀបចំឡើងតែពីរភាសា គឺភាសាអង់គ្លេស និងភាសាជប៉ុន។
  - ២. ភ្ជាប់កិច្ចសន្យាអនុវត្តវិធានការចត្តាឡីស័កចំនួន១៤ថ្ងៃ (ច្បាប់ដើម) ដែលផ្តល់ឱ្យដោយក្រុមហ៊ុន ឬសមាគមនៅប្រទេសជប៉ុន (ចំណុចទី៤ខាងលើ) ជូនការិយាល័យទទួលបន្ទុកអនុវត្តចត្តាឡីស័កនៅព្រលានយន្តហោះ។
  - ៣. បើសិនជាអាច សូមទាញយកកម្មវិធី Covid-19 Contact-Confirming Application ទៅក្នុងទូរស័ព្ទដៃ និងចុះឈ្មោះក្នុងកម្មវិធី មុនពេលចេញដំណើរទៅដល់ប្រទេសជប៉ុន។

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

❖ ពេលទៅដល់ប្រទេសជប៉ុន កម្មសិក្សាការី-ពលករជំនាញ ត្រូវអនុវត្តដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ ក្នុងអំឡុងពេលចត្តាឡីស័កចំនួន១៤ថ្ងៃ

២. អនុវត្តគោលការណ៍ចត្តាឡីស័កចំនួន ១៤ថ្ងៃ ដែលរៀបចំដោយក្រុមហ៊ុន ឬសមាគមនៃប្រទេសជប៉ុន។

***<u>សម្គាល់៖</u>*** *ក្នុងករណីដែលកម្មសិក្សាការី-ពលករជំនាញ មិនអនុវត្តតាមគោលការណ៍ណែនាំនៅប្រទេសជប៉ុន អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសជប៉ុន នឹងចាត់វិធានការតាមផ្លូវច្បាប់។*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសមាគមទីភ្នាក់ងារជ្រើសរើសឯកជន ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងកម្មសិក្សាការី-ពលករជំនាញដែលត្រៀមចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន ជ្រាបជាព័ត៌មាន និងសហការអនុវត្តឱ្យមានប្រសិទ្ធភាព។

ថ្ងៃ ពុធ ៧រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>ចម្លងជូន</u>**

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)

-សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)

-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់

"ដើម្បីជួយផ្សព្វផ្សាយ និងសហការ"

-ឯកសារ-កាលប្បវត្តិ